**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព

លេខ : ១២៧ បទ.ប្រក

# ប្រកាស

## ស្តីពីការ បង្កើតក្រុមការងារ ដើម្បីរៀបចំអនុវត្ត ឱ្យមាន ប្រសិទ្ធិភាព នៃគំរោងប្រាក់កម្ចី (JBIC)

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពី ការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការកែសំរួល និងបំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ/បក ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៣ ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញលិខិតលេខ DAII/2005-375-1 ចុះថ្ងៃ ១៧ ខែ មីនា ឆ្នាំ ២០០៦ របស់ធនាគារសំរាប់សហប្រតិបត្តិការអន្តរជាតិ នៃប្រទេស ជប៉ុន ( JBIC ) ។
- បានឃើញលិខិតលេខ CP-P5/E-001 ចុះថ្ងៃ ១០ ខែ មេសា ឆ្នាំ ២០០៦ របស់ធនាគារសំរាប់សហប្រតិបត្តិការអន្តរជាតិ នៃប្រទេស ជប៉ុន ( JBIC ) ។
- បានឃើញលិខិតលេខ ២២៥ ទ.ក ច ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៦ របស់ទូរគមនាគមន៍កម្ពុជា ។
- យោងតាមការងារចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១ :** បង្កើតក្រុមការងារមួយរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ដែលមានសមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១-លោក | ញ៉ុក | កោសលវិទ្យា | អគ្គនាយកទូរគមនាគមន៍កម្ពុជា | ប្រធាន |
| ២-លោក | ម៉ូវ | ចរិយា | អគ្គនាយករងទូរគមនាគមន៍កម្ពុជា | អនុប្រធាន |

| | | | | |
|---|---|---|---|---|
| ៣-លោក | អ៊ុច | រិទ្ធី | ប្រធាននាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងពត៌មាន | សមាជិក |
| ៤-លោក | អ៊ឹម | វុទ្ធា | ប្រធាននាយកដ្ឋានហិរញ្ញកិច្ច និង គណនេយ្យ | សមាជិក |
| ៥-លោក | ប៉ាល់ | វុឌ្ឍិកា | អនុប្រធាននាយកដ្ឋានផែនការហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក | តុល | ញ៉ាក់ | អនុប្រធានបច្ចេកវិទ្យាគមនាគមន៍ និងពត៌មាន | សមាជិក |
| ៧-លោក | វ៉ាង | ចាន់រិទ្ធី | អនុប្រធាននាយកដ្ឋានទូរគមនាគមន៍ក្នុងប្រទេស | សមាជិក |
| ៩-លោក | ស៊ុន | ចំរើន | មន្ត្រីទូរគមនាគមន៍កម្ពុជា | សមាជិក |
| ១០-លោក | ហ៊ុន | ប្រុស | មន្ត្រីទូរគមនាគមន៍កម្ពុជា | សមាជិក |
| ១១-លោក | ហេង | សុខវិសេស | មន្ត្រីទូរគមនាគមន៍កម្ពុជា | សមាជិក |
| ១២-លោក | នុត | មុនីរត្ន | មន្ត្រីទូរគមនាគមន៍កម្ពុជា | សមាជិក |
| ១៣-លោក | ហ៊ត | សុត្ថារិទ្ធ | មន្ត្រីទូរគមនាគមន៍កម្ពុជា | សមាជិក |
| ១៤-អ្នកស្រី | ឱម | ចរិយា | មន្ត្រីទូរគមនាគមន៍កម្ពុជា | សមាជិក |
| **១៥-មន្ត្រី ០១ រូប តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** | | | | សមាជិក |

**ប្រការ ២ :** ក្រុមការងារ ខាងលើនេះ មានភារកិច្ច :

-សហការការងារ ជាមួយធនាគារសំរាប់សហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន ( JBIC ) ដើម្បីអនុវត្តឱ្យមានប្រសិទ្ធិភាព នៃ គំរោងប្រាក់កម្ចី សំរាប់អនុវត្តគំរោងបណ្តាញឆ្អឹងខ្នងទូរគមនាគមន៍ មហាអនុតំបន់មេគង្គ " The Greater Mekong Telecommunications Backbone Network Project ( Cambodia Growth Corridor ) " ។

-ចប់ភារកិច្ច ត្រូវរាយការណ៍ពីលទ្ធផលការងារ ជូន ***ឯកឧត្តមរដ្ឋមន្ត្រី*** ។

**ប្រការ ៣ :** ក្រុមការងារខាងលើ នេះ ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ ***លោកប្រធាន*** និង អាចចាត់តាំងក្រុមការងារជំនាញផ្សេងទៀត តាមការងារចាំបាច់ ។

**ប្រការ ៤ :** រាល់ប្រកាសទាំងឡាយណា ដែលផ្ទុយពីខ្លឹមសារ នៃ ប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** អគ្គនាយកដ្ឋានរដ្ឋបាល ទូរគមនាគមន៍កម្ពុជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អស់លោក ដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្ត ឱ្យមានប្រសិទ្ធិខ្ពស់ តាមខ្លឹមសារ នៃ ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ , ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៦

រដ្ឋមន្ត្រី

ឡូវ..ឈ្មួន

<u>កន្លែងទទួល</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
"<u>ដើម្បីជូនជ្រាប</u>"
-ដូចប្រការ ៥ "<u>ដើម្បីអនុវត្ត</u>"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ